# កិច្ចប្រជុំត្រៀម
# រៀបចំកិច្ចប្រជុំលើកទី១១របស់ គ.ជ.អ.ប

សាលប្រជុំលេខាធិការដ្ឋាន ថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១៥

# កិច្ចប្រជុំត្រៀម
# រៀបចំកិច្ចប្រជុំលើកទី១១របស់ គ.ជ.អ.ប

សាលប្រជុំលេខាធិការដ្ឋាន ថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១៥

# របាយការណ៍សង្ខេប
# ស្តីពី
# កិច្ចដំណើរការផ្ទេរមុខងារ និងធនធានទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ

# វឌ្ឍនភាពនៃកិច្ចដំណើរការផ្ទេរមុខងារ

| កំពុងរៀបចំ បញ្ជីមុខងារ | បានបញ្ជប់ បញ្ជីមុខងារ | បានបញ្ជប់ ពិនិត្យមុខងារ |
|---|---|---|
| 1. ក្រសួងទេសចរណ៍ | 1. ក្រសួងអភិវឌ្ឍន៍ជនបទ | 1. ក្រសួងអភិវឌ្ឍន៍ជនបទ |
| 2. ក្រសួងវប្បធម៌ | 2. ក្រសួងកសិកម្ម | 2. ក្រសួងអប់រំ |
| 3. ក្រសួងពាណិជ្ជកម្ម | 3. ក្រសួងសុខាភិបាល | 3. ក្រសួងសង្គមកិច្ច |
| 4. ក្រសួងឧស្សាហកម្ម | 4. ក្រសួងអប់រំ | 4. ក្រសួងបរិស្ថាន |
| 5. ក្រសួងរ៉ែ និងថាមពល | 5. ក្រសួងសង្គមកិច្ច | 5. ក្រសួងសុខាភិបាល |
| 6. ក្រសួងសាធារណការ | 6. ក្រសួងបរិស្ថាន | |
| 7. ក្រសួងរៀបចំដែនដី | | |
| 8. ក្រសួងធនធានទឹក | | |

# ក្រសួងអប់រំ

- **ចំនួនមុខងារដែលបានកំណត់ក្នុងរបាយការណ៍៖**
  - មុខងារ៖ ១១
  - មុខងាររង៖ ៨០
  - អនុមុខងាររង/សកម្មភាព៖ ៥៧៣
- **ចំនួនមុខងារដែលស្នើផ្ទេរ៖** មុខងារចំនួន ២ រួមមាន
  - ការអប់រំកុមារតូច (ស្នើផ្ទេរមុខងាររងចំនួន៦/៣៤)
  - ការអប់រំក្រៅប្រព័ន្ធ (ស្នើផ្ទេរមុខងាររងចំនួន១/៤២)
- **ការរៀបចំសម្រាប់ការផ្ទេរ៖**
  - ក្រុមការងារបច្ចេកទេសបាន និងកំពុងសិក្សាដើម្បីលើកសំណើជូនថ្នាក់ដឹកនាំក្រសួង និងគ.ជ.អ.ប អំពីការផ្ទេរមុខងារៈ ១. **ការគ្រប់គ្រងបឋមសិក្សា** ២. **ការអប់រំកុមារតូច** និង៣. **ការអប់រំក្រៅប្រព័ន្ធ** ទៅឱ្យរដ្ឋបាលថ្នាក់ក្រុង ស្រុក

# ក្រសួងសុខាភិបាល

- **ចំនួនមុខងារដែលបានកំណត់ក្នុងរបាយការណ៍៖**
  - មុខងារ៖ ៥
  - មុខងាររង៖ ៣១
  - អនុមុខងាររង/សកម្មភាព៖ ៨០
- **ការរៀបចំសម្រាប់ការផ្ទេរ៖**
  - អនុវត្តសាកល្បងការធ្វើប្រតិភូកម្មនូវមុខងារផ្តល់សេវាសុខភាពនៅមណ្ឌលសុខភាពក្នុងស្រុកចំនួន៥នៅក្នុងខេត្តចំនួន២ គឺខេត្តបាត់ដំបង និងខេត្តពោធិសាត់
  - ក្រុមការងារបច្ចេកទេសបាន និងកំពុងសិក្សាដើម្បីលើកសំណើជូនថ្នាក់ដឹកនាំក្រសួង និងគ.ជ.អ.ប លើការផ្ទេរមុខងារគ្រប់គ្រងស្រុកប្រតិបត្តិ **មន្ទីរពេទ្យបង្អែកស្រុក និងមណ្ឌលសុខភាពដែលមានវិសាលភាពគ្របដណ្តប់ក្នុងដែនសមត្ថកិច្ចនៃស្រុក១** ទៅឱ្យរដ្ឋបាលថ្នាក់ស្រុកទាំងនោះ

# ក្រសួងអភិវឌ្ឍន៍ជនបទ

- **ចំនួនមុខងារដែលបានកំណត់ក្នុងរបាយការណ៍៖**
  - មុខងារ៖ ៩
  - មុខងាររង៖ ៣៨
- **ចំនួនមុខងារដែលស្នើផ្ទេរ៖** មុខងាររងចំនួន៥ រួមមាន
  - ការលើកកម្ពស់សន្តិសុខស្បៀងគ្រួសារ
  - អនាម័យជនបទ (សាកល្បងក្នុងស្រុកចំនួន១០)
  - ជួសជុលប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទ(សាកល្បងក្នុងស្រុកចំនួន០៧)
  - ដាក់ផ្លាកសញ្ញាចរាចរណ៍លើផ្លូវជនបទ
  - ជួសជុលផ្លូវជនបទមានលក្ខណៈជាប្រចាំ
- **ការរៀបចំសម្រាប់ការផ្ទេរ៖**
  - អនុវត្តសាកល្បងផ្ទេរមុខងារអនាម័យជនបទ (ស្រុកចំនួន១០) និងមុខងារជួសជុលប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត (ស្រុកចំនួន០៧)
  - ក្រុមការងារបច្ចេកទេសបាន និងកំពុងសិក្សាដើម្បីលើកសំណើជូនថ្នាក់ដឹកនាំក្រសួង និង គ.ជ.អ.ប ក្នុងការផ្ទេរមុខងារ**សាងសង់ និងជួសជុលផ្លូវជនបទ (ប្រភេទទី២ ទី៣ និងទី៤)** ទៅឱ្យរដ្ឋបាលក្រុង ស្រុក

# ក្រសួងបរិស្ថាន

- **ចំនួនមុខងារដែលបានកំណត់ក្នុងរបាយការណ៍៖**
  - មុខងារ៖ ៨
  - មុខងាររង៖ ៤០
- **ចំនួនមុខងារដែលស្នើផ្ទេរ៖** មុខងាររងចំនួន៥ រួមមាន
  - ការពង្រឹងការគ្រប់គ្រងសំណល់រឹង រាវ តាមទីប្រជុំជន និងតាមទីសាធារណៈ
  - ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ឬកិច្ចសន្យាការពារបរិស្ថាននៃគម្រោងវិនិយោគ
  - ការគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិ
  - ការបញ្ជ្រាបភាពធន់នឹងការប្រែប្រួលអាកាសធាតុ
  - ការពង្រឹងការងារអប់រំបរិស្ថាន (ក្នុងប្រព័ន្ធ ក្រៅប្រព័ន្ធ)
- **ការរៀបចំសម្រាប់ការផ្ទេរ៖**
  - បានរៀបចំបញ្ចប់សេចក្តីព្រាងអនុក្រឹត្យស្តីពីការគ្រប់គ្រងសំរាម និងសំណល់រឹងនៅតាមទីប្រជុំជន (ផ្ទេរមុខងារគ្រប់គ្រងសំរាម និងសំណល់រឹងតាមទីប្រជុំជនទៅឱ្យរដ្ឋបាលក្រុង ស្រុក)
  - បាន និងកំពុងរៀបចំសេចក្តីព្រាងប្រកាសសម្រាប់ការផ្ទេរមុខងារចំនួន៤ផ្សេងទៀត រួមមាន ១. ការគ្រប់គ្រងតំបន់ការពារធម្មជាតិ ២. ការគ្រប់គ្រងសហគមន៍ ៣. ការបញ្ជ្រាបភាពធននឹងអាកាសធាតុ និង៤. ការពង្រឹងការងារអប់រំបរិស្ថាន

# ក្រសួងសង្គមកិច្ច

- **ចំនួនមុខងារដែលបានកំណត់ក្នុងរបាយការណ៍៖**
  - មុខងារ៖ ៨
  - មុខងាររង៖ ៣៧
  - អនុមុខងាររង (សកម្មភាព)៖ ១៤២
- **ចំនួនមុខងារដែលស្នើផ្ទេរឆ្នាំ២០១៥៖** មុខងាររងចំនួន ៥ រួមមាន
  - ផ្តល់សេវាថែទាំកុមារកំព្រា និងកុមារងាយរងគ្រោះនៅក្នុងមណ្ឌល
  - ផ្តល់សេវាថែទាំកុមារកំព្រា និងកុមារងាយរងគ្រោះនៅក្នុងគ្រួសារ និងសហគមន៍
  - ចុះកិច្ចព្រមព្រៀងជាមួយអង្គការជាតិ និងអន្តរជាតិ
  - ផ្តល់ជំនួយសង្គ្រោះបន្ទាន់សម្រាប់ជនរងគ្រោះ និងជនងាយរងគ្រោះ
  - ស្រង់ទិន្នន័យជនរងគ្រោះ និងជនងាយរងគ្រោះ
- **ការរៀបចំសម្រាប់ការផ្ទេរ៖**
  - បាន និងកំពុងរៀបចំសេចក្តីព្រាងប្រកាស និងសេចក្តីណែនាំសម្រាប់ការផ្ទេរមុខងារ ៖ ១. ការគ្រប់គ្រងមណ្ឌលថែទាំកុមាររបស់រដ្ឋទៅឱ្យខេត្តបាត់ដំបង ២. ការគ្រប់គ្រងមណ្ឌលថែទាំកុមាររបស់អង្គការមិនមែនរដ្ឋាភិបាលទៅឱ្យក្រុង ស្រុកចំនួន១០ ក្នុងខេត្តបាត់ដំបង និង៣. ការផ្តល់សេវាថែទាំកុមាររងគ្រោះនៅក្នុងសហគមន៍ទៅឱ្យឃុំ សង្កាត់ក្នុងក្រុង ស្រុកទាំង១០ខាងលើ

# បញ្ហាប្រឈមសំខាន់ៗ

- ភាពយឺតយ៉ាវនៃការរៀបចំសេចក្តីសម្រេចរួម
- នីតិវិធីនៃកិច្ចដំណើរការរៀបចំត្រូវចំណាយពេលច្រើន
- ក្រុមការងាររបស់ក្រសួង ស្ថាប័នមានភាពមមាញឹកនឹងការងារស្នូលរបស់ខ្លួន
- យន្តការផ្ទេរធនធានហិរញ្ញវត្ថុ
- យន្តការផ្ទេរធនធានមនុស្ស

# អរគុណ